លេខ៧៦ ចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦
អត្ថបទប្រចាំសប្តាហ៍ | Weekly Article
No. 76 Published on February 11, 2026

# ករណីសិក្សា៖ បរធនបាលកិច្ច TATA

## Case Study: TATA Trusts



https://www.tatatrusts.org/about-tatatrusts/the-tata-trusts-story

**ក្រុមហ៊ុន Tata (Tata Group)** ត្រូវបានបង្កើតឡើងដោយលោក **Jamsetji Tata** ក្នុងឆ្នាំ១៨៦៨ ដែលជាសហគ្រាសសកល មានទីស្នាក់ការកណ្តាលនៅក្នុងប្រទេសឥណ្ឌា ព្រមទាំងមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន ៣១ គ្របដណ្តប់ដោយវិស័យជាច្រើនផ្សេងៗគ្នា។ ជាទស្សនវិស័យរបស់លោក Jamsetji Tata ការប្រកបអាជីវកម្មជោគជ័យគឺមិនអាស្រ័យលើការរកប្រាក់ចំណេញសម្រាប់ខ្លួនឯងតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រើប្រាស់ទ្រព្យសម្បត្តិ និងផលចំណេញ ដើម្បីអភិវឌ្ឍសង្គម និងជាតិទាំងមូលក្នុងរយៈវែង។ ជាមួយនឹងទស្សនវិស័យបែបនេះ លោក Jamsetji Tata បានបង្កើត **បរធនបាលកិច្ច TATA (Tata Trusts)** ដែលជាបណ្តុំមូលនិធិសប្បុរសធម៌ធំជាងគេមួយនៅប្រទេសឥណ្ឌា ក្នុងឆ្នាំ១៨៩២ ក្នុងគោលបំណងដើម្បីលើក-កម្ពស់ការអប់រំកម្រិតឧត្តមសិក្សា និងការស្រាវជ្រាវសម្រាប់ប្រជាជនឥណ្ឌា។ បន្ទាប់ពី លោក Jamsetji Tata បានទទួលមរណភាពក្នុងឆ្នាំ១៩០៤ ក្រុមហ៊ុន Tata Group ត្រូវបានគ្រប់គ្រង និងកាន់កាប់ភាគហ៊ុនចំនួន ៦៦% ដោយកូនប្រុសទាំង ២រូប របស់លោក Jamsetji Tata គឺ៖ **លោក Dorabji Tata** និង**លោក Ratan Tata** ព្រមទាំងបានបន្តបេសកកម្មសប្បុរសធម៌នៃបរធនបាលកិច្ច TATA ផងដែរ។ ផលចំណេញមួយចំនួនដែលទទួលបានពីការវិនិយោគរបស់ក្រុមហ៊ុន Tata (**បរធនបាលទាយក**) ត្រូវបានផ្ទេរទៅបរធនបាលកិច្ច TATA សម្រាប់ផ្តល់ជាប្រយោជន៍ដល់សាធារណៈ (**អត្ថគាហកៈ**) ក្នុងគោលបំណង

បង្កើតគំនិតផ្តួចផ្តើមសប្បុរសធម៌ក្នុងវិស័យជាច្រើន ដូចជា៖ សុខភាព អាហារូបត្ថម្ភ ការអប់រំ ទឹក និងអនាម័យ ជីវភាពរស់នៅ យុត្តិធម៌សង្គម និងការរួមបញ្ចូល ជំនាញ ការធ្វើចំណាកស្រុកនិងនគរូបនីយកម្ម បរិស្ថាន អក្ខរកម្មឌីជីថល កីឡា សិល្បៈ សិប្បកម្ម និងវប្បធម៌ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍជំនាញផ្សេងៗជាដើម។

ក្នុងរយៈពេលប្រមាណជាង ១៣០ ឆ្នាំកន្លងមកនេះ បរធនបាលកិច្ច TATA បានក្លាយជាបណ្តុំមូលនិធិសប្បុរសធម៌ធំជាងគេមួយនៅប្រទេសឥណ្ឌា ដែលមានមូលនិធិសប្បុរសធម៌ផ្សេងៗបានចូលរួមជាមួយបរធនបាលកិច្ច TATA ក្នុងការផ្តល់ផលប្រយោជន៍ដល់សាធារណជនទូទៅក្នុងប្រទេសឥណ្ឌា និងចូលរួមដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ផងដែរ។

**Tata Group** was founded by **Jamsetji Tata** in 1868 and is a global enterprise headquartered in India with 31 companies across multiple verticals. Jamsetji Tata's vision was that successful business should not be based solely on making one's profits, but should use assets and profits for the long-term development of society and the nation as a whole. With this vision in mind, **Jamsetji Tata** established the **TATA Trusts** in 1892 which one of the largest philanthropic foundations in India, with the aim of promoting higher education and research for the people of India. After Jamsetji Tata's death in 1904, the Tata Group was held 66% by Jamsetji Tata's two sons, **Dorabji Tata** and **Ratan Tata**, who continued the charitable mission of the TATA Trusts. Some of the profits earned from Tata Group (**Trustor**) are transferred to TATA Trusts for public benefit (**Beneficiary**) to undertake philanthropic initiatives in various sectors such as: health, nutrition, education, water and sanitation, livelihoods, social justice and inclusion, skills, migration and urbanization, environment, digital literacy, sports, arts, crafts and culture, disaster management and skill development, etc.

Over the past 130 years, TATA Trusts has become one of the largest philanthropic foundations in India, with various philanthropic foundations joining TATA Trusts in benefiting the public in Indian people and contributing to social and economic development.

អត្ថបទ៖ កញ្ញា កេត ស្រីនិច | Article: Name: Ms. Ket Sreynich

ឯកសារយោង | References:
- ច្បាប់ស្តីពីបរធនបាលកិច្ច
- https://www.tatatrusts.org/
- https://www.hindustantimes.com/business/how-tata-trusts-controls-tata-sons-the-company-that-owns-all-other-tata-companies-101728708176014.html
- https://news.abplive.com/business/tata-trusts-noel-tata-chairman-ratan-tata-what-role-does-it-play-in-tata-group-explained-1723767
- https://www.tbsnews.net/world/south-asia/how-tata-trusts-controls-tata-sons-company-owns-all-other-tata-companies-964686

ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.